**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០១៦ សណន

ថ្ងៃ ចន្ទ ១៤ កើត ខែ ស្រាពណ៍ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២០

**ជម្រាបជូន**

- **លោកប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តកែប**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តកំពត**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តស្វាយរៀង**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ**

**កម្មវត្ថុៈ** សេចក្តីណែនាំស្តីពីការអនុវត្តវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យទេសចរណ៍ជុំទី៥។

**យោងៈ** សេចក្តីប្រកាសព័ត៌មានស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា អំពីវិធានការបន្ថែមដើម្បីគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗនៃសេដ្ឋកិច្ចជាតិ នៅក្នុងបរិការណ៍នៃវិបត្តិ និងការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ (ជុំទី៥, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** ជ្រាបថា អនុវត្តតាមសេចក្តីប្រកាសព័ត៌មានស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាអំពីវិធានការបន្ថែម ដើម្បីគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗនៃសេដ្ឋកិច្ចជាតិនៅក្នុងបរិការណ៍នៃវិបត្តិ និងការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ជុំទី៥ ក្រសួងទេសចរណ៍សូមណែនាំ **លោកប្រធានមន្ទីរទេសចរណ៍** ចុះផ្សព្វផ្សាយ និងជំរុញជាបន្ទាន់ដល់ម្ចាស់អាជីវកម្មសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងទីភ្នាក់ងារទេសចរណ៍នូវវិធានការមួយចំនួន ដូចខាងក្រោមៈ

១. បន្តលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទចំពោះសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងទីភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត ក្រុងបាវិត និងក្រុងប៉ោយប៉ែត សម្រាប់រយៈពេល០២ខែបន្ថែមទៀត ចាប់ពីខែសីហា ដល់កញ្ញា ឆ្នាំ២០២០។

២. ជូនដំណឹងដល់ម្ចាស់អាជីវកម្មសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងទីភ្នាក់ងារទេសចរណ៍ដែលបានព្យួរ ឬនឹងត្រូវព្យួរ ដាក់ពាក្យស្នើសុំព្យួរកិច្ចសន្យាការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមរយៈមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ដើម្បីទទួលបានប្រាក់ឧបត្ថម្ភ ៤០ដុល្លារអាមេរិកក្នុងមួយខែសម្រាប់រយៈពេល០២ខែបន្តទៀតចាប់ពីខែសីហា ដល់ខែកញ្ញា ឆ្នាំ២០២០ ពីរាជរដ្ឋាភិបាល។ សហគ្រាស និងអាជីវកម្មក្នុងវិស័យទេសចរណ៍ត្រូវរួមចំណែកតាមគោលការណ៍ស្ម័គ្រចិត្ត និងតាមលទ្ធភាពជាក់ស្តែងបន្ថែមលើអ្វីដែលរាជរដ្ឋាភិបាលបានផ្តល់ជូន។

អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធានមន្ទីរ** ជ្រាប និងអនុវត្ត តាមការគួរ។

សូម **លោកប្រធានមន្ទីរ** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះពីខ្ញុំ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**ធិត ចន្ថា**

<u>ចម្លងជូន៖</u>

- សហព័ន្ធទេសចរណ៍កម្ពុជា (CTF)
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)
- សមាគមសណ្ឋាគារកម្ពុជា (CHA)
- សមាគមភោជនីយដ្ឋានកម្ពុជា (CRA)
- សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា (PATA)
- ឯកសារកាលប្បវត្តិ

<u>ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖</u>

០៩២ ៧៧៩ ៨៣៣

០៨៩ ៧៦៧ ៦៦៤